សលាកប័ត្រព័ត៌មាន៖ កម្រងអត្ថបទសិទ្ធិជាមូលដ្ឋាន៖ សេរីភាពខាងព័ត៌មាន

សេរីភាពមូលដ្ឋាន៖ សេរីភាពខាងព័ត៌មាន/សេរីភាពខាងការបញ្ចេញមតិ

រូបភាពរួម៖ សេរីភាពខាងព័ត៌មានត្រូវគេបានទទួលស្គាល់ជាសាកលថាជាសិទ្ធិមូលដ្ឋានរបស់មនុស្ស និងជាជំនឿគន្លឹះនៃលទ្ធិប្រជាធិបតេយ្យ។ រាជរដ្ឋាភិបាលកម្ពុជា (“រ.ដ.ក”) បានប្រកាសការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីផ្តល់សិទ្ធិទទួលបានព័ត៌មាន តែទោះជាយ៉ាងនេះក្តី សិទ្ធិទទួលបានព័ត៌មាន ការប្រើប្រាស់ព័ត៌មាន និង តម្រូវការព័ត៌មានហាក់ដូចជានៅឆ្ងាយពីសង្គមកម្ពុជា។

សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះផ្តល់នូវទិដ្ឋភាពរួមនៃសេរីភាពខាងព័ត៌មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) និងអំពាវនាវឲ្យលើកយកសេចក្តីព្រាងច្បាប់ស្តីពីសេរីភាពទទួលបានព័ត៌មាន ដែលបានបង្កើតឡើងថ្មីៗនេះមកជជែកពិភាក្សា និងអនុម័ត។ សលាកប័ត្រព័ត៌មាននេះចងក្រងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

គោលការណ៍នៃសេរីភាពខាងព័ត៌មាន

សេរីភាពខាងព័ត៌មានដែលក៏សំដៅទៅលើ“សិទ្ធិក្នុងការយល់ដឹង” ឬ “សិទ្ធិទទួលបានព័ត៌មាន” ត្រូវបានគេទទួលស្គាល់ជាសាកលថាជាសិទ្ធិមូលដ្ឋានរបស់មនុស្ស និងត្រូវបានភ្ជាប់ពីកំណើតទៅនឹងសិទ្ធិជាច្រើនផ្សេងៗទៀត។ ការទទួលបានព័ត៌មានក៏ត្រូវភ្ជាប់ផងដែរទៅនឹងធាតុចម្បងនៃអភិបាលកិច្ចល្អ មានដូចជា៖ តម្លាភាព និងទំនួលខុសត្រូវ ហើយក៏មានសារៈសំខាន់ក្នុងការកសាងទំនុកចិត្ត និងជំនឿចំពោះរដ្ឋាភិបាល។ បើគ្មានការទទួលបានព័ត៌មានទេនោះ ប្រជាពលរដ្ឋនឹងមិនបានដឹងអំពីបញ្ហាទាំងឡាយដែលជះឥទ្ធិពលដោយផ្ទាល់លើការរស់នៅរបស់ពួកគេ។ សរុបសេចក្តីមក សេរីភាពខាងព័ត៌មានជាជំនឿមូលដ្ឋានក្នុងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ និងជាអ្វីសម្រាប់ឆ្លុះបញ្ចាំងពីភាពខុសគ្នារវាងរដ្ឋាភិបាលតាមបែបប្រជាធិបតេយ្យ និងរបបដឹកនាំដោយគ្មានទំនួលខុសត្រូវ និងប្រតិបត្តិសកម្មភាពរបស់ពួកគេក្នុងភាពអាថកំបាំង។

ច្បាប់ស្តីពីសេរីភាពឧច្ចលបានព័ត៌មាន

អនុលោមតាមច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស សេរីភាពខាងព័ត៌មានត្រូវបានការពារជាផ្នែកនៃសិទ្ធិសេរីភាពខាងការបញ្ចេញមតិដូចដែលបានចែងនៅក្នុងមាត្រា១៩ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (“ស.ប.ស.ម”) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ក.អ.ស.ព.ន”) ដែលបញ្ញត្តថា *“បុគ្គលគ្រប់រូបមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ហើយសិទ្ធិនេះរួមបញ្ចូលទាំងសេរីភាពស្វែងរក ទទួល និងផ្តល់ឲ្យនូវព័ត៌មាន”*។ មានច្បាប់មួយចំនួនដែលធានាការទទួលបានព័ត៌មាន បើទោះបីជាគ្មានអត្ថបទច្បាប់ជាក់លាក់ស្តីពីសេរីភាពទទួលបានព័ត៌មានដែលត្រូវបានអនុម័តនៅកម្ពុជាក៏ដោយ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (“រដ្ឋធម្មនុញ្ញ”)៖ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញការពារសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិដែលទាក់ទិននឹងសេរីភាពខាងព័ត៌មាន។ ម៉្យាងវិញទៀត មាត្រា៣១ នៃរដ្ឋធម្មនុញ្ញធានាទទួលស្គាល់ និងគោរពតាម“ស.ប.ស.ម” កាតិកាសញ្ញា និងអនុសញ្ញាទាំងឡាយដែលទាក់ទិននឹងសិទ្ធិមនុស្ស ហើយដែលរួមបញ្ចូលមាត្រា១៩ នៃ“ស.ប.ស.ម” និង“ក.អ.ស.ព.ន”។

ច្បាប់ស្តីពីបណ្ណសារ (ឆ្នាំ២០០៥)៖ ច្បាប់ស្តីពីបណ្ណសារកំណត់លើការគ្រប់គ្រង និងការថែរក្សាព័ត៌មាននៅក្នុងបណ្ណសារដ្ឋានរដ្ឋាភិបាល ដែលផ្តល់ការស្វែងរក និងប្រើប្រាស់សម្រាប់ការសិក្សាស្រាវជ្រាវ និងពិគ្រោះពិភាក្សាដោយសេរីចំពោះ“ឯកសារសាធារណៈ”ដែលមិននាំឲ្យអន្តរាយដល់សន្តិសុខជាតិ។ ទោះជាយ៉ាងនេះក្តី ច្បាប់នេះមិនបញ្ជាក់ឲ្យច្បាស់អំពីប្រភេទនៃព័ត៌មានដែលចាត់ទុកថាជា“ឯកសារសាធារណៈ”នោះទេ។

ច្បាប់ស្តីពីរបបសារព័ត៌មាន (ឆ្នាំ១៩៩៥)៖ មាត្រា៥ នៃច្បាប់ស្តីពីរបបសារព័ត៌មានទទួលស្គាល់សិទ្ធិរបស់អ្នកសារព័ត៌មានក្នុងការ“ទទួលបាននូវព័ត៌មាននៅក្នុងកំណត់ត្រាដែលកាន់កាប់ដោយរដ្ឋាភិបាល”។ ការទទួលបានអាចត្រូវបានច្រានចោលដោយផ្អែកលើមូលហេតុសន្តិសុខជាតិ ការជ្រៀតជ្រែកសិទ្ធិឯកជនរបស់បុគ្គល ព័ត៌មានសម្ងាត់ និងនៅពេលណាដែលការបង្ហាញអាចបង្កគ្រោះថ្នាក់ដល់មន្ត្រីរាជការសាធារណៈក្នុងការបំពេញតួនាទីរបស់ពួកគេ។ ច្បាប់នេះអនុវត្តតែទៅលើសមាជិកនៃអ្នកសារព័ត៌មាន ហេតុដូច្នេះ ប្រជាពលរដ្ឋខ្មែរសាមញ្ញមិនអាចទទួលបានព័ត៌មាននៅក្នុងកំណត់ត្រាដែលកាន់កាប់ដោយរដ្ឋាភិបាលដោយផ្អែកលើច្បាប់នេះបានទេ។

ច្បាប់អង្គការស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ (ឆ្នាំ២០០៨) ("ច្បាប់អង្គការ")៖ ច្បាប់អង្គការដែលបង្កើតជាផ្នែកនៃគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ – មានគោលដៅធ្វើប្រតិភូកម្មអំណាចជាក់លាក់ ព្រមទាំងទំនួលខុសត្រូវ និងការគ្រប់គ្រងរដ្ឋបាលទៅឲ្យអាជ្ញាធរមូលដ្ឋាន – រួមបញ្ចូលទាំងបទប្បញ្ញត្តិក្នុងការទទួលបានព័ត៌មានជាក់លាក់ ដូចជា៖ បទប្បញ្ញត្តិដែលចែងថារាល់ការប្រជុំក្រុមប្រឹក្សាទាំងអស់ត្រូវតែធ្វើឡើងជាសាធារណៈ និងក្រុមប្រឹក្សាបង្កើតលក្ខខណ្ឌអនុគ្រោះសម្រាប់សាធារណៈជន នៅពេលផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីរបាយការណ៍ កំណត់ហេតុនៃអង្គប្រជុំ បទបញ្ជាអាជ្ញាធរមូលដ្ឋាន ។ល។ (មាត្រា៥១) បន្ទាប់ពីអនុម័តគម្រោងផែនការណ៍អភិវឌ្ឍន៍នានា ក្រុមប្រឹក្សាត្រូវបិទផ្សាយគម្រោងនោះជាសាធារណៈ (មាត្រា ៤១) និងក្រុមប្រឹក្សានីមួយៗត្រូវក្តាប្រកាសព័ត៌មានសាធារណៈ ឬមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀតដែលផ្តល់ភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានសាធារណៈ (មាត្រា៥២)។

ការផ្តត់ផ្តង់ និងតម្រូវការព័ត៌មាន

ការផ្តត់ផ្តង់៖ រ.ដ.ក បានបង្ហាញការប្តេជ្ញាមួយចំនួនចំពោះសេរីភាពទទួលបានព័ត៌មាននៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានធ្វើសេចក្តីព្រាងអត្ថបទគោលនយោបាយនៅក្នុងខែសីហា ឆ្នាំ ២០០៧។ ការតែងតាំងមន្ត្រីអ្នកនាំពាក្យដើម្បីឆ្លើយតបការចោទសួរនៅតាមក្រសួងភាគច្រើន ហើយក៏ដូចជាការបង្កើតអង្គភាពព័ត៌មាន និងប្រតិកម្មរហ័សបានជួយសម្រួលដល់លំហូរនៃព័ត៌មាន។ ប៉ុន្តែមន្ត្រីអាជ្ញាធរនៅតែខកខានក្នុងចែករំលែកព័ត៌មានឲ្យបានត្រឹមត្រូវក្នុងកម្រិតជាអតិប្បរមា ដែលអាចឲ្យប្រជាពលរដ្ឋសង្កេតមើលសកម្មភាពរបស់អ្នកកាន់អំណាច។ ចំណងជិតស្និទ្ធរវាងរដ្ឋាភិបាល ឬអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយសមាជិករដ្ឋាភិបាល និងធុរៈកិច្ច មានន័យថាមានកង្វះខាតក្នុងការលើកទឹកចិត្តឲ្យផ្តល់ព័ត៌មានអំពីការផ្តល់កិច្ចសន្យាសាធារណៈ ថ្វីបើមានច្បាប់ជាក់លាក់តម្រូវឲ្យមានការបញ្ចេញយ៉ាងដូច្នោះ។ ហេតុដូច្នេះ ព័ត៌មានពេញលេញទាក់ទងនឹងដីធ្លី និងធនធានមិនទាន់អាចរកបាននៅឡើយទេ និងធ្វើឲ្យមានគម្លាតរវាងអ្នកមាន និងអ្នកក្រកាន់តែឆ្ងាយទៅៗ។

តម្រូវការ៖ តាមទម្លាប់ឃើញថាមានវប្បធម៌គោរពកោតខ្លាចចំពោះអាជ្ញាធរដោយប្រជាពលរដ្ឋខ្មែរមានការស្ទាក់ស្ទើរក្នុងការស្នើសុំព័ត៌មានពីមន្ត្រីរាជការ។ ការសិក្សាមួយរបស់ធនាគារពិភពលោកឆ្នាំ២០០៩ បានរកឃើញថាប្រជាពលរដ្ឋខ្មែរមិនបានយល់ថាជាតួនាទីរបស់ខ្លួនក្នុងការទាមទារឲ្យអាជ្ញាធរដោះស្រាយបញ្ហារបស់ពួកគេ ដោយភ័យខ្លាចថាការស្នើសុំអាចត្រូវបានគេបកស្រាយថាជាបង្ហាញការមិនទុកចិត្ត និងអាចបង្កឲ្យមានកំហឹង បាត់បង់កេរ្តិ៍ឈ្មោះ ឬបង្ខំយអរិជ្ជមានផ្សេងៗ។ ប៉ុន្តែបច្ចុប្បន្ន ប្រជាពលរដ្ឋកំពុងតែខិតខំស្វែងរកសំលេងរបស់ពួកគេកាន់តែច្រើនឡើងក្នុងទាមទារព័ត៌មាន ជាពិសេសបញ្ហាបណ្តេញចេញពីដីធ្លីដ៏រាំរ៉ៃ និងអំពើពុករលួយរបស់មន្ត្រីរាជការ។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ទោះបីជាមានជំហានវិជ្ជមានសំខាន់ៗឆ្ពោះទៅរកការគោរព ការពារ និងការបំពេញសិទ្ធិទទួលបានព័ត៌មាន យើងឃើញថានៅមានកង្វះខាតធន្ធៈនយោបាយដើម្បីបោះជំហានចុងក្រោយក្នុងការអនុម័តច្បាប់ និងធានាថារចនាសម្ព័ន្ធ និងការប្រតិបត្តិសំខាន់ៗត្រូវបានដាក់ចេញដើម្បីជួយគាំទ្រដល់ការអនុវត្តន៍ច្បាប់។ នៅក្នុងខែធ្នូ ឆ្នាំ២០១០ សេចក្តីស្នើច្បាប់ដែលចេញពីអ្នកតាក់តែងច្បាប់របស់គណៈបក្សសម រង្ស៊ីត្រូវបានដាក់នៅចំពោះមុខរដ្ឋសភា និងក្រោយមកត្រូវបានច្រានចោលទាំងស្រុងភ្លាមៗ។ ការកែប្រែសេចក្តីស្នើច្បាប់ត្រូវបានដាក់ជាថ្មីនៅក្នុងខែមីនា ឆ្នាំ២០១២។ រ.ដ.ក និងរដ្ឋសភាគប្បីពិចារណាសេចក្តីស្នើច្បាប់នេះឲ្យបានត្រឹមត្រូវ ដោយរួមទាំងអញ្ជើញអ្នកពិគ្រោះលើសេចក្តីស្នើច្បាប់ជាសាធារណៈ និងអនុម័តច្បាប់ស្តីពីសេរីភាពទទួលបានព័ត៌មាន។ ទោះជាយ៉ាងណាក៏ដោយ រាល់នីតិបញ្ញត្តិទាមទារនូវបម្លាស់ប្តូរអំពីវិធីពិនិត្យមើលព័ត៌មាន និងកែប្រែទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល។ តម្រូវការព័ត៌មានកើនឡើងរបស់ប្រជាពលរដ្ឋ និងការទទួលស្គាល់ជាសមាមាត្រអំពីសារៈសំខាន់នៃសារព័ត៌មានដោយមន្ត្រីរាជការសាធារណៈនឹងក្លាយជាធាតុចម្បងដើម្បីបន្តការអភិវឌ្ឍន៍លើវិស័យនយោបាយ សង្គម និងសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជានាពេលអនាគត។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង លោក អ៊ូ វីរៈ តាមរយៈទូរស័ព្ទលេខ (៨៥៥) ១២ ៥០ ៥០ ៥១ ឬតាមរយៈអ៊ីមែល ouvirak@cchrcambodia.org ឬកញ្ញា សាណា ហ្គោស តាមរយៈលេខ (៨៥៥) ៨៩ ៦១ ៤៣ ៣៥ ឬតាមរយៈអ៊ីមែល sana.ghouse@cchrcambodia.org។